ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EA) ស្តីពីការស្តារឡើងវិញនូវផ្លូវរត់យន្តហោះ ១៤R-៣២L និងការប្តូរទីតាំងផ្លូវតភ្ជាប់ B

King County International Airport
Boeing Field

ខ្មែរ | Khmer

ចែករំលែកមតិយោបល់លើសេចក្តីព្រាងការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EA) សម្រាប់ការស្តារផ្លូវរត់ និងការប្តូរទីតាំងផ្លូវតភ្ជាប់នៅអាកាសយានដ្ឋាន KCIA



ផ្លូវរត់យន្តហោះដែលបង្ហាញជាពណ៌ខ្មៅនៅលើផែនទីខាងលើ ដែលហៅថាផ្លូវរត់ 14R-32L គឺកំពុងឈានដល់ទីបញ្ចប់នៃអាយុកាលប្រើប្រាស់របស់វាហើយ។ កម្រាលផ្លូវនៅលើផ្លូវរត់យន្តហោះ ចាំបាច់ត្រូវស្តារឡើងវិញ ដើម្បីអនុញ្ញាតឱ្យមានប្រតិបត្តិការប្រកបដោយសុវត្ថិភាពជាបន្តបន្ទាប់សម្រាប់យន្តហោះ។ ផ្លូវតភ្ជាប់ដែលបង្ហាញជាពណ៌ប្រផេះនៅលើផែនទីដែលជាផ្លូវតភ្ជាប់ B ត្រូវតែប្តូរទីតាំង ដើម្បីបំពេញតាមស្តង់ដាបច្ចុប្បន្នរបស់រដ្ឋបាលអាកាសចរណ៍សហព័ន្ធ (FAA)។ តំបន់សិក្សាគម្រោងមួយចំនួនគឺស្ថិតនៅក្រៅព្រំប្រទល់បច្ចុប្បន្នរបស់ KCIA។

អាកាសយានដ្ឋានអន្តរជាតិខោនធី King (KCIA) កំពុងរៀបចំស្តារផ្លូវរត់យន្តហោះចម្បងរបស់ខ្លួនគឺ ផ្លូវរត់យន្តហោះ 14R-32L និងប្តូរទីតាំងផ្លូវតភ្ជាប់ B ពី 50 ទៅ 75 ហ្វីត ទៅទិសខាងលិចនៃផ្លូវរត់យន្តហោះ 14R-32L ដើម្បីបំពេញតាមស្តង់ដាបច្ចុប្បន្នរបស់ FAA។ KCIA ជាមួយរដ្ឋបាលអាកាសចរណ៍សហព័ន្ធ (FAA) កំពុងរៀបចំការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EA) ស្របតាមច្បាប់ស្តីពីគោលនយោបាយបរិស្ថានជាតិ (NEPA) ដែលវិភាគលើផលប៉ះពាល់បរិស្ថានដែលអាចកើតមានពីគម្រោងនេះ។ សមាជិកសហគមន៍ អ្នកជួលក្នុងអាកាសយានដ្ឋាន ទីភ្នាក់ងារ និងភាគីដែលមានចំណាប់អារម្មណ៍ ត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំតាមប្រព័ន្ធនិម្មិត និងកម្មវិធីបើកទ្វារស្វាគមន៍សាធារណជនដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខ ដើម្បីស្វែងយល់បន្ថែម និងចែករំលែកមតិយោបល់លើសេចក្តីព្រាង EA។

មូលហេតុដែលគម្រោងនេះចាំបាច់ត្រូវមាន

King County International Airport
Boeing Field

KCIA បានស្តារផ្លូវរត់យន្តហោះ 14R-32L ឡើងវិញចុងក្រោយនៅឆ្នាំ 2006 ហើយវាកំពុងឈានដល់ទីបញ្ចប់នៃអាយុកាលប្រើប្រាស់របស់វាហើយ។ លើសពីនេះ ផ្លូវតភ្ជាប់ B គឺនៅជិតផ្លូវរត់យន្តហោះ 14R-32L ពេក ក្រោមស្តង់ដាបច្ចុប្បន្នរបស់ FAA។ ដើម្បីបំពេញតាមស្តង់ដានាពេលបច្ចុប្បន្ន ផ្លូវតភ្ជាប់នេះត្រូវតែប្តូរទីតាំងពី 50 ទៅ 75 ហ្វីត ទៅទិសខាងលិចនៃផ្លូវរត់យន្តហោះ 14R-32L។

គម្រោង

KCIA ស្នើឡើងដើម្បី៖

- ស្តារផ្លូវរត់យន្តហោះ 14R–32L ឡើងវិញ
- ប្តូរទីតាំងផ្លូវតភ្ជាប់ B ប្រហែល 50 ទៅ 75 ហ្វីត ទៅទិសខាងលិច
- បញ្ចប់ការកែលម្អដែលពាក់ព័ន្ធ ដូចជា៖
  - រុះរើ និងប្តូរទីតាំងប៉មត្រួតពិនិត្យចរាចរណ៍អាកាសយានដ្ឋាន (ATCT) និងអគារសង្គ្រោះ និងពន្លត់អគ្គិភ័យយន្តហោះ (ARFF)
  - សាងសង់ទីតាំងប្រព័ន្ធទឹកភ្លៀង
  - ប្តូរទីតាំងផ្នែកខ្លះនៃរបងបរិវេណជុំវិញ
  - ការកាត់បន្ថយផលប៉ះពាល់ដល់អ្នកជួល និងផ្នែកលើដី

កំពុងដំណើរការពេលនេះ៖ សេចក្តីព្រាងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EA)

ច្បាប់ស្តីពីគោលនយោបាយបរិស្ថានជាតិ (NEPA) គឺជាច្បាប់សហព័ន្ធដែលតម្រូវឱ្យទីភ្នាក់ងារសហព័ន្ធពិចារណាលើផលប៉ះពាល់បរិស្ថាន និងបង្ហាញផលប៉ះពាល់ទាំងនោះជាសាធារណៈ។ KCIA កំពុងធ្វើការជាមួយ FAA ទីភ្នាក់ងារសហគមន៍មូលដ្ឋាន និងភាគីដែលមានចំណាប់អារម្មណ៍ ដើម្បីចែករំលែកព័ត៌មាន និងប្រមូលមតិយោបល់ដែលជាផ្នែកមួយនៃដំណើរការ EA។

KCIA បានរៀបចំកម្មវិធីបើកទ្វារស្វាគមន៍សាធារណជន ដើម្បីកំណត់វិសាលភាពទាក់ទងនឹងដំណើរការនេះ កាលពីខែមេសា ឆ្នាំ 2026។ KCIA បានបញ្ចូលមតិយោបល់សាធារណៈដែលអាចអនុវត្តបានពីដំណាក់កាលកំណត់វិសាលភាព ទៅក្នុងសេចក្តីព្រាង EA។ ក្រុមការងារគម្រោងបានវិភាគលើផលប៉ះពាល់បរិស្ថានដែលអាចកើតមាន និងបានរៀបចំសេចក្តីព្រាង EA។ KCIA និង FAA នឹងបោះពុម្ពផ្សាយសេចក្តីព្រាង EA សម្រាប់ការពិនិត្យ និងផ្តល់មតិយោបល់ពីសំណាក់ទីភ្នាក់ងារ និងសាធារណជន ហើយនឹងផ្តល់ការជូនដំណឹងនៅពេលដែលសេចក្តីព្រាង EA មានសម្រាប់ការពិនិត្យ។ KCIA នឹងចែករំលែកការវិភាគបរិស្ថានដែលមាននៅក្នុងសេចក្តីព្រាង EA នៅក្នុងកិច្ចប្រជុំតាមប្រព័ន្ធនិម្មិត និងកម្មវិធីបើកទ្វារស្វាគមន៍សាធារណជនដោយផ្ទាល់ ក្នុងខែតុលា ឆ្នាំ 2026 និងប្រមូលមតិយោបល់លើសេចក្តីព្រាង EA រហូតដល់ថ្ងៃទី 14 ខែវិច្ឆិកា ឆ្នាំ 2026។

KCIA នឹងពិចារណាលើមតិយោបល់ដែលប្រមូលបានក្នុងអំឡុងពេលនៃដំណាក់កាលកំណត់វិសាលភាពនេះ ខណៈពេលដែលខ្លួនអភិវឌ្ឍ EA។ បន្ទាប់៖

- ក្រុមការងារគម្រោងឆ្លើយតបទៅនឹងមតិយោបល់លើសេចក្តីព្រាង EA និងរៀបចំ EA ចុងក្រោយ។
- KCIA និង FAA បោះពុម្ពផ្សាយ EA ចុងក្រោយ។
- FAA នឹងចេញសេចក្តីសម្រេចអំពីការរកឃើញថាមិនមានផលប៉ះពាល់ធ្ងន់ធ្ងរ (FONSI) ឬ FAA នឹងរៀបចំសេចក្តីថ្លែងការណ៍អំពីផលប៉ះពាល់បរិស្ថាន (EIS)។

របៀបចូលរួម

ចូលរួមជាមួយពួកយើងនៅក្នុងកិច្ចប្រជុំសេចក្តីព្រាង EA នាពេលខាងមុខ។ KCIA នឹងរៀបចំកិច្ចប្រជុំតាមប្រព័ន្ធនិម្មិត និងកម្មវិធីបើកទ្វារស្វាគមន៍សាធារណជនដោយផ្ទាល់ ហើយនឹងចែករំលែកព័ត៌មានដូចគ្នានៅក្នុងកិច្ចប្រជុំទាំងពីរ។ សមាជិកសហគមន៍ អ្នកជួលក្នុងអាកាសយានដ្ឋាន ទីភ្នាក់ងារ និងភាគីដែលមានចំណាប់អារម្មណ៍ ត្រូវបានអញ្ជើញឱ្យស្វែងយល់អំពីគម្រោង សួរសំណួរ និងផ្តល់មតិយោបល់លើសេចក្តីព្រាង EA។

កិច្ចប្រជុំតាមប្រព័ន្ធនិម្មិត

- **•ថ្ងៃពុធ ទី 14 ខែតុលា ឆ្នាំ 2026**
- **ម៉ោង 11:30 ព្រឹក - 12:30 រសៀល (PDT)**

kingcounty.zoom.us/webinar/register/WN_PTbHxeVUSWm3e7f668SWQw

សូមស្នើសុំតម្រូវការបកប្រែផ្ទាល់មាត់ជា ភាសាសញ្ញាអាមេរិក (ASL) កាតាំង ខ្មែរ ចិនកុកងឺ អេស្ប៉ាញ តាហ្គាឡុក ឬវៀតណាម តាមទូរសព្ទ ឬអ៊ីមែល ត្រឹមថ្ងៃទី 30 ខែកញ្ញា។

កម្មវិធីបើកទ្វារស្វាគមន៍សាធារណជនដោយផ្ទាល់

- **ថ្ងៃពុធ ទី 14 ខែតុលា ឆ្នាំ 2026**
- **ម៉ោង 6:00 – 7:30 ល្ងាច (PDT)**
- **•សេវាបកប្រែផ្ទាល់មាត់មានជា៖**
  ភាសាសញ្ញាអាមេរិក (ASL) កាតាំង ខ្មែរ ចិនកុកងឺ អេស្ប៉ាញ តាហ្គាឡុក និងវៀតណាម។
- **KCIA Flight Service Station**
  6526 Ellis Avenue S., Seattle, WA 98108

មិនអាចចូលរួមកិច្ចប្រជុំសេចក្តីព្រាង EA បានទេឬ?

KCIA នឹងផ្តល់ការជូនដំណឹងនៅពេលសេចក្តីព្រាង EA មានសម្រាប់ការពិនិត្យ។ វានឹងមាននៅលើគេហទំព័រគម្រោង។
kingcounty.gov/airport/taxiway-b-nepa

ដាក់ស្នើមតិយោបល់តាមរយៈ អ៊ីមែលទៅកាន់៖

KCIACommunityoutreach@kingcounty.gov
Attn: Eric Miller

ដាក់ស្នើមតិយោបល់តាមប្រៃសណីយ៍ទៅកាន់៖

Eric Miller, Capital Project Manager
King County International Airport
7277 Perimeter Road South, Suite 200
Seattle, WA 98108

រាល់មតិយោបល់ទាំងអស់ត្រូវតែដាក់បញ្ជូននៅចន្លោះ **ថ្ងៃទី 14 ខែតុលា – ថ្ងៃទី 13 ខែវិច្ឆិកា ឆ្នាំ 2026។**